# SMASHED ONLINE

# មគ្គុទេសក៍គ្រូបង្រៀន

# និវេទន៍របស់យើង

និវេទន៍របស់យើងបង្ហាញពីជំនឿរបស់យើងអំពីរបៀបដែលយើងដោះស្រាយបញ្ហានៃការពិសាគ្រឿងស្រវឹងពេលមិនទាន់គ្រប់អាយុ និងអារម្មណ៍នៃការពង្រឹងអំណាចដែលយើងចង់បង្កើតឡើងចំពោះយុវវ័យ។

SMASHED គឺជាការអប់រំដែលនាំឱ្យមានការផ្លាស់ប្តូរជីវិត

ដោះស្រាយបញ្ហានៃការពិសាគ្រឿងស្រវឹងមិនទាន់គ្រប់អាយុតាមរយៈការគិតជាវិជ្ជមាន

ដើម្បីបង្កើតឡើងនូវជំនាន់មួយដែលមានការត្រៀមលក្ខណៈតទល់នឹងសម្ពាធពីមិត្តភក្តិ នឹងមានការរៀបចំខ្លួន ប្រឆាំងនឹងឥទ្ធិពលអវិជ្ជមាន

ចំណេះដឹងគឺជាថាមពល

នៅពេលដែលអ្នកកំពុងមានភាពពិបាកដោយមានក្តារសង្ស័យ និងភាពមិនច្បាស់លាស់ សូមមានការរៀបចំខ្លួនដោយប្រើព័ត៌មាន និងការយល់ដឹង

ហើយនៅពេលដែលចៀសពីស្ថានភាពនេះមិនរួច សូមត្រៀមខ្លួនដើម្បីធ្វើការសម្រេចចិត្តដោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយមួយ នោះគឺ

SMASHED។ ការអប់រំអំពីគ្រឿងស្រវឹង ដើម្បីផ្តល់អំណាចដល់មនុស្សជំនាន់ក្រោយ។

# អំពី SMASHED

យុវជនមានសិទ្ធិទទួលបានការអប់រំអំពីគ្រឿងស្រវឹងដែលមានលក្ខណៈស្មោះត្រង់ ផ្តល់អំណាច និងបែបបំផុសគំនិត។ យើងចង់ក្លាយជាចលករផ្លាស់ប្តូរជាវិជ្ជមានសម្រាប់យុវជនដប់លាននាក់ត្រឹមឆ្នាំ 2030។ Smashed មានដំណើរការនៅក្នុងជាងម្ភៃប្រាំប្រទេសនៅជុំវិញពិភពលោក។

# តើ SMASHED ONLINE គឺជាអ្វី ?

Smashed Online មានភាពស្រស់ស្រាយ សប្បាយរីករាយ និងមានលក្ខណៈចូលរួម ដោយមានរួមបញ្ចូលនូវវិនាដកម្មដែលមានភាពទាក់ទាញរួមជាមួយនឹងការសិក្សា និងការពិភាក្សាដែលមានលក្ខណៈអន្តរកម្ម។ វិនាដកម្មនេះរៀបរាប់អំពីរឿងរ៉ាវដ៏មានអនុភាព និងប្រាកដនិយមអំពីយុវជន និងគ្រឿងស្រវឹង។ សិស្សត្រូវបានលើកទឹកចិត្តឱ្យសួរខ្លួនឯងថា 'ចុះបើជាខ្ញុំវិញ ?'

# កម្មវត្ថុសិក្សា

សិស្សសង្កេត ស្វែងយល់ និងឆ្លុះបញ្ចាំងលើប្រធានបទសំខាន់ៗស្តីពីការពិសារគ្រឿងស្រវឹងពេលមិនទាន់គ្រប់អាយុ៖

- មូលហេតុផ្នែកសង្គម និងផ្លូវអារម្មណ៍
- ផលប៉ះពាល់លើជីវិតរស់នៅរបស់មនុស្សវ័យក្មេង
- ផលប៉ះពាល់ដល់សង្គម និងការធ្វើការសម្រេចចិត្ត
- ទីកន្លែង និងរបៀបជួយខ្លួនអ្នក និងអ្នកដទៃ

# របៀបប្រើប្រាស់ SMASHED ONLINE

## សិស្សម្នាក់ៗ

- សិស្សអាចទទួលបានតំណដើម្បីចូលទៅកាន់វគ្គសិក្សា ចុះឈ្មោះដោយអនាមិក និងបញ្ចប់វគ្គសិក្សាទៅតាមពេលវេលារបស់ពួកគេផ្ទាល់
- សម្រាប់អ្នកប្រើប្រាស់ជាបុគ្គលម្នាក់ៗ គឺមានរយៈពេល 60 ទៅ 90 នាទី ដែលរួមបញ្ចូលទាំងភាពយន្ត និងធាតុដែលមានលក្ខណៈអន្តរកម្មច្រើនទៀត
- សិស្សបញ្ចប់ការស្ទង់មតិលក្ខណៈអនាមិកសាមញ្ញមួយ នៅដើម និងនៅចុងបញ្ចប់នៃវគ្គសិក្សា
- តំណភ្ជាប់ដែលមានប្រយោជន៍ទៅកាន់ជំនួយបន្ថែម ដំបូន្មាន និងព័ត៌មានបន្ថែម ត្រូវបានផ្ដល់ជូននៅចុងបញ្ចប់វគ្គ
- សិស្សអាចទាញយកវិញ្ញាបនបត្រផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីបង្ហាញថាពួកគេបានបញ្ចប់វគ្គសិក្សានៅលើ Smashed Online ហើយ

## ម៉ោងសិក្សាក្នុងថ្នាក់ជាក្រុម

- អ្នកអាចចែកចាយវគ្គសិក្សានៅក្នុងថ្នាក់រៀនដោយប្រើប៊ូតុង 'សម្រាប់គ្រូបង្រៀន' នៅលើទំព័រដើម
- វគ្គនេះនឹងត្រូវការពេលពី 45 ទៅ 60 នាទីដោយប្រើក្ដារខៀនលក្ខណៈអន្តរកម្ម ឬកុំព្យូទ័រយួរដៃ និងឧបករណ៍បញ្ចាំងស្លាយ
- វគ្គសិក្សានេះរួមមានវីដេអូភាគដែលមានលក្ខណៈទាក់ទាញ ការពិភាក្សាតាមពេលកំណត់ និងអន្តរកម្មតួអង្គ
- អ្នកអាចចូលរៀនវគ្គជាច្រើនបាន ហើយបន្តរៀនវគ្គសិក្សាណាដែលមិនទាន់បានបញ្ចប់ ពីកន្លែងដែលអ្នកបានចាកចេញ
- សកម្មភាពបោះឆ្នោតនឹងបង្ហាញពីវឌ្ឍនភាពនៃថ្នាក់រៀន ដោយមានវិញ្ញាបនបត្រថ្នាក់រៀនដែលមានលក្ខណៈ ផ្ទាល់ខ្លួនឱ្យទាញយក

# ការបង្រៀនសម្រាប់ម៉ោងសិក្សាជាក្រុម

ប្រសិនបើអ្នកកំពុងដឹកនាំម៉ោងសិក្សាជាក្រុម ចូរទាញយកអត្ថប្រយោជន៍ឱ្យបានច្រើនបំផុតពីបទពិសោធន៍នេះ ដោយអនុវត្តតាមដំបូន្មានខាងក្រោម៖

## មុនពេលមេរៀន

- ចុះឈ្មោះ និងរៀបចំគណនីគ្រូបង្រៀនរបស់អ្នកនៅលើ Smashed Online
- បើកមើលវគ្គសិក្សាដើម្បីធ្វើឱ្យខ្លួនអ្នកស៊ាំជាមួយនឹងមាតិកា និងមុខងារជាមុន
- ត្រូវប្រាកដថា អ្នកគិតថា Smashed Online គឺសមស្របសម្រាប់ក្រុមអាយុគោលដៅរបស់អ្នក

## អ្នកនឹងត្រូវការ

- កុំព្យូទ័រដែលមានភ្ជាប់អ៊ីនធឺណិត និងការដំឡើងប្រព័ន្ធសំឡេង និងរូបភាពសមស្រប
- ចូលទៅកាន់ Smashed Online ដោយឡុកចូលគណនីគ្រូបង្រៀនរបស់អ្នក
- ចូលប្រើក្តារចុច និងម៉ៅស៍/បន្ទះប៉ះ សម្រាប់ការបញ្ចូលលទ្ធផលបោះឆ្នោតថ្នាក់ ឈ្មោះថ្នាក់ និងការរុករកវគ្គសិក្សា

## គន្លឹះ និងដំបូន្មាន

- សម្រាប់សកម្មភាពបោះឆ្នោត ចូរប្រើសកម្មភាព Heads Down Hands Up ( ឱនក្បាលចុះ លើកដៃឡើង ) ដើម្បីធ្វើឱ្យចម្លើយរបស់សិស្សមានលក្ខណៈអនាមិក
- ជួយឱ្យសកម្មភាពពិភាក្សាមានលក្ខណៈអន្តរកម្មតាមដែលអាចធ្វើទៅបាន ដោយសិស្សពិភាក្សាអំពីគំនិតជាគូ ឬជាក្រុម មុនពេលផ្តល់មតិកែលម្អនៅក្នុងថ្នាក់
- ប្រើអ្នកស្ម័គ្រចិត្តដើម្បីសម្រេចចិត្តថាតើត្រូវសួរសំណួរណាមួយក្នុងអំឡុងពេលជជែកជាវីដេអូលក្ខណៈអន្តរកម្ម។ ប្រសិនបើអ្នកមានពេលច្រើនទៀត សូមស្នើឱ្យក្រុមបោះឆ្នោតជ្រើសរើសជម្រើសពេញនិយមបំផុត
- Smashed Online អាចចែកចាយបានតិចដល់ 45 នាទី និងស័ក្តិសម ដល់មេរៀនដែលមានរយៈពេល 60 នាទី
- ងាយស្រួលពង្រីកវគ្គសិក្សាទៅលើមេរៀនមួយផ្សេងទៀត ដោយអនុញ្ញាតឱ្យមានពេលវេលាបន្ថែមសម្រាប់សកម្មភាពពិភាក្សាជាក្រុម
- កុំភ្លេចទាញយកវិញ្ញាបនបត្រដែលមានលក្ខណៈផ្ទាល់ខ្លួនដែលមានឈ្មោះថ្នាក់នៅចុងបញ្ចប់នៃវគ្គសិក្សា!

# បង្កប់ការសិក្សា

បទពិសោធន៍នេះនឹងធ្វើឱ្យសិស្សចាប់អារម្មណ៍នឹងបញ្ហានៃការពិសារគ្រឿងស្រវឹងពេល មិនទាន់គ្រប់អាយុ។ ហេតុអ្វីមិនបន្តការសិក្សា? នេះគឺជាគំនិតសាមញ្ញៗមួយចំនួនដែលអ្នកអាចលើកមកបង្រៀននៅក្នុងថ្នាក់។

## សំណួរខ្លីៗ

បង្កើតសំណួរខ្លីៗសម្រាប់សិស្សស្តីពីគ្រឿងស្រវឹង និងគ្រោះថ្នាក់របស់វា។ រួមបញ្ចូលសំណួរផ្សេងៗអំពីអ្វីដែលបានកើតឡើងនៅក្នុងសាច់រឿងរបស់ Smashed រួមទាំងផលវិបាកនៃការពិសារស្រាសម្រាប់តួអង្គនីមួយៗ។

## ការរចនាក្រាហ្វិក / សិល្បៈ

សិស្សអាចបង្ហាញពីការស្វែងយល់អំពីបញ្ហានៃការពិសារស្រាពេលមិនទាន់គ្រប់អាយុ តាមរយៈបង្កើតផ្ទាំងរូបភាព ឬពាណិជ្ជកម្មតាមអ៊ីនធឺណិត។ លើកទឹកចិត្តពួកគេឱ្យប្រើបញ្ហាប្រឈម និងភាព ខ្វល់ខ្វាយចិត្តដែលតួអង្គជួបប្រទះនៅក្នុងសាច់រឿង។

## វិនាដកម្ម

ប្រើសាច់រឿងជាការបំផុសគំនិតសម្រាប់ដើម្បីសិស្ស បង្កើតឈុតឆាក ការផ្សាយពាណិជ្ជកម្ម និងការសម្តែងផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងការពិសារ ស្រាពេលមិនទាន់គ្រប់អាយុ។ ជួយពួកគេឱ្យស្វែងយល់អំពីសម្ពាធពីមិត្តភក្តិ និងបង្កើតឆុតឆាកបញ្ចប់ផ្សេងៗទៀតនៅលើ Smashed!

## ការសរសេរបែបច្នៃប្រឌិត

សិស្សស្រមៃថាពួកគេជាមិត្តភក្តិ ឬសាច់ញាតិរបស់តួអង្គនៅចំណុចមួយក្នុងខ្សែភាពយន្ត។ តើពួកគេប្រហែលជាអាចផ្តល់យោបល់អ្វីខ្លះដល់តួអង្គតាមអ៊ីមែល ឬសំបុត្រ? ឬពួកគេអាចសរសេរអត្ថបទកាសែតអំពីឧប្បត្តិហេតុនៅចុងបញ្ចប់នៃសាច់រឿងបាន។

## ការប្រកួតប្រជែង

មនុស្សវ័យក្មេងជារឿយៗមានគំនិតល្អបំផុត។ ដំណើរការការប្រកួតប្រជែងដោយឱ្យពួកគេប្រកួតប្រជែងដើម្បីបង្កើតយុទ្ធនាការស្តីពីគ្រោះថ្នាក់នៃការពិសារស្រាពេលមិនទាន់គ្រប់អាយុដោយបង្ហាញការងាររបស់ពួកគេដល់អ្នកដទៃ។

## ប្រព័ន្ធផ្សព្វផ្សាយ

សិស្សអាចបង្កើតឡើងវិញនូវឈុតឆាកនានាពី Smashed អំពីខ្សែភាពយន្ត ឬផលិតជាវីដេអូឯកសារអំពីគ្រោះថ្នាក់នៃការពិសារស្រាពេលមិនទាន់គ្រប់អាយុ។

# វក្យាទំនាក់ទំនង

សូមអរគុណចំពោះការប្រើប្រាស់ Smashed នៅក្នុងសាលារៀន និងជួយយុវជនឱ្យបានរៀនអំពីបញ្ហានៃការពិសារស្រាពេលមិនទាន់គ្រប់អាយុ។ យើងក៏សង្ឃឹមថា Smashed បានផ្ដល់នូវបទពិសោធន៍សិក្សាប្រកបដោយភាពច្នៃប្រឌិត ប្លែកគេ ដែលជួយពង្រឹងដល់កម្មវិធីសិក្សាផងដែរ។ សូមចែករំលែកបទពិសោធន៍របស់អ្នកអំពី Smashed ជាមួយពួកយើង និងគ្រូបង្រៀនផ្សេងទៀតផងដែរ!

## ផ្ទះមេត្តា

023218 987
mesterharm@gmx.net
Facebook.com/MetaHousePhnomPenh
meta-house.com

## SMASHED

Twitter.com/smashedproject
Facebook.com/smashedproject
www.smashedproject.org

Smashed គឺជាកម្មវិធីអប់រំសាកល ដែលត្រូវបានបង្កើតឡើងដោយ Collingwood នៅក្នុងចក្រភពអង់គ្លេស។ សូមអរគុណដល់ការឧបត្ថម្ភពី Diageo នៅកម្ពុជា ដែលធ្វើឱ្យ Smashed Online គឺឥតគិតថ្លៃសម្រាប់សាលារៀន។